**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ** **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

*ថ្ងៃអង្គារ ៨ រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧*
*រាជធានីភ្នំពេញ, ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៣*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី វឌ្ឍនភាពនៃការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ ឆ្នាំ២០២៣ ផ្អែកលើគោលការណ៍ គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព

នារសៀលថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៣ នៅសាលាភូមិន្ទរដ្ឋបាល ក្រសួងមុខងារសាធារណៈ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសហការរៀបចំសន្និសីទសារព័ត៌មានស្តីពី «**ការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំឆ្នាំ២០២៣**» ដោយមានការអញ្ជើញចូលរួមជាគណៈអធិបតីពីសំណាក់ **ឯកឧត្តម ហ៊ុន ម៉ានី** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង**ឯកឧត្តម ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ សន្និសីទសារព័ត៌មាននេះ មានគោលបំណងធ្វើវឌ្ឍភាពព័ត៌មានជូនបេក្ខជន និងសាធារណជន ឆ្ពោះទៅកាន់ការប្រឡងជ្រើសរើសមន្ត្រីកសិកម្មឃុំ ឆ្នាំ២០២៣ ចំនួន២៥០កន្លែង ដើម្បីឱ្យចូលបម្រើការជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្អែកលើគោលការណ៍ គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព។

ការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ ឆ្នាំ២០២៣ត្រូវបានប្រកាសបើកឱ្យបេក្ខជនចុះឈ្មោះប្រឡងប្រជែងតាមប្រព័ន្ធអនឡាញចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣។ ក្រោយការដាក់ពាក្យត្រូវបានបញ្ចប់ បេក្ខជនដែលបានចាប់អារម្មណ៍ និងចុះឈ្មោះក្នុងប្រព័ន្ធមានចំនួន**១២,៧៤៤នាក់**។ ក្នុងចំណោមបេក្ខជនដែលបានចូលប្រើប្រាស់ប្រព័ន្ធដូចបានរៀបរាប់ខាងលើ មានបេក្ខជនចំនួន**៧,៤២២នាក់** បានបំពេញ និងដាក់ពាក្យ ចូលរួមប្រឡងប្រជែង។ ទោះបីជាយ៉ាងនេះក្តី បេក្ខជនដែលបានដាក់ពាក្យទាំងអស់ត្រូវបំពេញតាមលក្ខខណ្ឌ ដែលស្របតាមនីតិវិធីនៃការប្រឡង និងមានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីក្លាយខ្លួនជាមន្ត្រីកសិកម្មឃុំ ជាពិសេសត្រូវមានជំនាញឯកទេស ឬបានឆ្លងកាត់វគ្គបណ្តុះបណ្តាលដែលមានកម្រិតចាប់ពីវិញ្ញាបនបត្រឡើងទៅពាក់ព័ន្ធទៅនឹងវិស័យកសិកម្ម។ ជាលទ្ធផលបឋម បេក្ខជនដែលត្រូវបានអនុម័តឱ្យចូលរួមប្រឡងមានចំនួន **៣,៣២៩នាក់**។ បេក្ខជនដែលទទួលបានអនុម័តរួចរាល់ហើយ អាចពិនិត្យផ្ទៀងផ្ទាត់ឈ្មោះ និងកែតម្រូវលើព័ត៌មានរបស់ខ្លួនតាមរយៈតំណ https://lms.era.gov.kh/qrlink/31 ចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៣ ត្រឹមម៉ោង ៥រសៀលជាកំហិត។

ថ្លែងក្នុងសន្និសីទសារព័ត៌មាន **ឯកឧត្តម ហ៊ុន ម៉ានី** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ បានលើកឡើងថា *"ចាប់តាំងពីដំណាក់កាលផ្សព្វផ្សាយ ទាំងការដាក់ពាក្យ ទាំងការរៀបចំនីតិវិធីនានាសម្រាប់ដំណើរការជ្រើសរើសប្រឡង និងកំណែប្រឡង សុទ្ធតែត្រូវបានឆ្លងកាត់ការពិភាក្សា និងការគិតគូរពិចារណាយ៉ាងហ្មត់ចត់បំផុតដោយគណៈកម្មការជំនាញអន្តរក្រសួង ធ្វើយ៉ាងណាធានាដល់ការរៀបចំប្រព័ន្ធជ្រើសរើសមួយដែលផ្តល់ឱកាសស្មើៗគ្នា មាន តម្លាភាព មានយុត្តិធម៌ និងផ្អែកលើសមត្ថភាពពិតប្រាកដដូចអ្វីដែល* **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** *បានលើកឡើងថា "ការជ្រើសរើសមន្ត្រីត្រូវឈរលើគោលការណ៍* **«ជាប់ដោយមោទនៈ ធ្លាក់ដោយអស់ចិត្ត»។"** ឯកឧត្តមរដ្ឋមន្ត្រីបានបើកទូលាយចំពោះការចូលរួមពីសាធារណជនថា *"គណៈកម្មការរៀបចំការប្រឡងលើកទឹកចិត្តឱ្យមានការចូលរួមតាមដានជាប្រចាំទាំងអស់គ្នាលើដំណើរការនៃការប្រឡងក្នុងឆន្ទៈពិតប្រាកដចំពោះការកែទម្រង់រដ្ឋបាលសាធារណៈ និងសូមស្វាគមន៍រាល់មតិចូលរួមដើម្បីស្តាបនាជាវិជ្ជមាន។"*

គួររំលឹកផងដែរថា កាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៣ រាជរដ្ឋាភិបាលបានផ្តល់ការឯកភាពដល់ការជ្រើសរើសមន្ត្រីកសិកម្មចំនួន ១៦០០នាក់ ក្នុងរយៈពេល៣ឆ្នាំ ក្នុងនោះ ក្នុងឆ្នាំ២០២៣ ចំនួន២៥០នាក់, ក្នុងឆ្នាំ២០២៤ ចំនួន៨០០នាក់ និងក្នុងឆ្នាំ២០២៥ ចំនួន៥៥០នាក់ ដើម្បីបែងចែកទៅតាមឃុំ-សង្កាត់ដែលមានសកម្មភាពកសិកម្មនៅទូទាំងប្រទេស។ សម្រាប់ឆ្នាំ២០២៣ រាជរដ្ឋាភិបាលកម្ពុជារៀបចំជ្រើសរើសមន្ត្រីកសិកម្មឃុំចំនួន២៥០នាក់ ដើម្បីដាក់ពង្រាយនៅតាមឃុំចំនួន២៥០ ក្នុងស្រុកចំនួន៨៩ នៃខេត្តចំនួន១៧។ មន្ត្រីកសិកម្មឃុំ-សង្កាត់ទាំងអស់នឹងស្នាក់នៅជាអចិន្ត្រៃយ៍នៅមូលដ្ឋាន ដោយផ្សារភ្ជាប់ការងារនិងជីវភាពផ្ទាល់ជាមួយប្រជាកសិករប្រមូល ព័ត៌មានអំពីស្ថានភាពផលិតកម្មកសិកម្មនៅមូលដ្ឋាន ព្រមទាំងផ្តល់ព័ត៌មាន និងសំណូមពររបស់ប្រជាកសិករមកក្រសួងដើម្បីពិនិត្យ និងស្វែករកដំណោះស្រាយបានទាន់ពេលវេលា។

ទាក់ទងនឹងការជ្រើសរើសមន្ត្រីកសិកម្មឃុំនេះ **ឯកឧត្តម ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានលើកឡើងថា *"មន្ត្រីកសិកម្មឃុំដែលជ្រើសរើសថ្មី នឹងជួយផ្តល់ជំនាញបច្ចេកទេសទាន់ពេលវេលាដល់កសិករនៅតាមមូលដ្ឋានឃុំ-សង្កាត់សំដៅលើកកម្ពស់ជីវភាពនិងបង្កើនប្រាក់ចំណេញរបស់កសិករ ដោយកាត់បន្ថយថ្លៃដើមជាអតិបរមា។"*

សូមជម្រាបថា ការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ ឆ្នាំ២០២៣ នឹងប្រព្រឹត្តិទៅនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៣ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ចំពោះវិញ្ញាសាប្រឡងនឹងត្រូវបានរៀបចំជា៣ផ្នែកគឺ៖(១)វិញ្ញាសាសរសេរ ជំនាញកសិកម្ម រយៈពេល២ម៉ោង (២)វិញ្ញាសាពហុចម្លើយ រយៈពេល១ម៉ោង ដែលមានរួមបញ្ចូលគ្នានូវជំនាញកសិកម្ម និងចំណេះដឹង ទូទៅពាក់ព័ន្ធនឹងរដ្ឋបាលសាធារណៈ មុខងារសាធារណៈ ក្រមសីលធម៌ គណិតសាស្ត្រ ព័ត៌មានវិទ្យា ភូមិសាស្ត្រ និង(៣) វិញ្ញាសាសរសេរភាសាអង់គ្លេស រយៈពេល១ម៉ោង។ វិញ្ញាសាប្រឡងទាំងអស់នឹងត្រូវបានរៀបចំតាក់តែងក្នុងថ្ងៃតែមួយ ពោលគឺរៀបចំវិញ្ញាសានៅពេលព្រឹក ហើយចាប់ផ្តើមប្រឡងពីម៉ោង១២ថ្ងៃត្រង់តទៅ ក្រោមការចូលរួមសង្កេតការណ៍ពីអង្គភាពប្រឆាំងអំពើពុករលួយ និងសហភាពសហព័ន្ធយុវជនកម្ពុជា។ សន្លឹកកិច្ចការនីមួយៗ មានការចុះលេខសម្ងាត់ មានការកាត់ក្បាលសន្លឹកកិច្ច ហើយមានការពិនិត្យកំណែជាលើកទី២ មុនឈានដល់ការបូកពិន្ទុតាមប្រព័ន្ធអនាមិក។

បេក្ខជនដែលចូលរួមប្រឡងប្រជែងត្រូវគោរពវិន័យ និងបទបញ្ញតិនៃការប្រឡងឱ្យបានខ្ជាប់ខ្ជួន។ ក្នុងករណីបេក្ខជនប្រព្រឹត្តខុសពីបទបញ្ញត្តិប្រឡង ដូចជាបន្លំឯកសារ បន្លំបេក្ខភាព យកទូរស័ព្ទចូល។ល។ នឹងធ្លាក់ជាស្វ័យប្រវត្តិ លុបឈ្មោះចេញពីបញ្ជី និងដកចេញពីបេក្ខភាពប្រឡងរហូត ព្រមទាំងត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមានផ្សេងទៀតផងដែរ។ បេក្ខជនអាចចូលរួមពិនិត្យដំណើរការនៃការធ្វើកំណែរហូតដល់ការប្រកាសលទ្ធផល ហើយមានឱកាសប្ដឹងតវ៉ាក្នុងរយៈពេល១សប្ដាហ៍បន្ទាប់ពីចេញលទ្ធផលផ្អែកលើបែបបទ និងនីតិវិធីនៃការប្រឡងប្រជែង។ បេក្ខជនជ័យលាភីដែលបានប្រឡងជាប់ជាស្ថាពរក្លាយជាមន្ត្រីកសិកម្មឃុំ នឹង ត្រូវឆ្លងកាត់ការធ្វើកម្មសិក្សាមុនពេលត្រូវបានតាំងស៊ប់ក្នុងប្រភេទក្របខ័ណ្ឌ ក, ខ និងគ ផ្អែកលើកម្រិតបណ្ដុះបណ្ដាលរបស់សាមីខ្លួន។ មន្ត្រីកសិកម្មឃុំនឹងទទួលបានប្រាក់បៀវត្សទាបបំផុតចាប់ពី១,៤០០,០០០រៀល ទៅតាមប្រភេទក្របខ័ណ្ឌ និងទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែចំនួន ១៦០,០០០រៀល ក្នុងមួយខែ រួមទាំង អត្ថប្រយោជន៍ផ្សេងៗទៀតរបស់មន្ត្រីរាជការស៊ីវិល។ បេក្ខជនដែលបានជាប់ជាស្ថាពរ នឹងត្រូវបានចាត់បញ្ជូនទៅអនុវត្តកម្មសិក្សាការងារតាមគោលដៅនីមួយៗ ដោយមិនត្រូវបានអនុញ្ញាតិឱ្យផ្លាស់ប្ដូរទីកន្លែងបំពេញការងារដោយហេតុផលណាមួយឡើយ។ ក្នុងករណីដែលមានការស្នើសុំផ្លាស់ប្ដូរកន្លែងការងារ មានន័យថាសាមីជននោះបោះបង់ក្របខ័ណ្ឌមន្ត្រីរាជការ។

គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ ដែលមានក្រសួងមុខងារសាធារណៈ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, និងដោយមានការចូលរួមពីអង្គភាពប្រឆាំងអំពើពុករលួយ និងស្ថាប័នពាក់ព័ន្ធដទៃទៀត ប្ដេជ្ញារៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំឆ្នាំ២០២៣ ដោយឈរលើគោលការណ៍ គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅនឹងកំណែទម្រង់រដ្ឋបាលសាធារណៈ តាមរយៈការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រីរាជការព្រមទាំងសម្រេចឱ្យបាននូវចក្ខុវិស័យដឹកនាំប្រកបដោយភាពស្វាហាប់ និងមានថាមពលរបស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**៕